# ៤៨ម៉ោងចុងក្រោយរបស់លោកអនុសេនីយ៍ទោ ឡៀម ជាន

ថ្ងៃ ១៧ មេសា នយោបាយ និងស្ថានភាពសង្គ្រាមមានភាពច្របូកច្របល់ស្មុគស្មាញ ហើយមិនប្រាកដថា និងមានអ្វីកើតឡើងក្នុងពេលមួយម៉ោងខាងមុខនេះឡើយ ។ ក្នុងដំណើរត្រឡប់មកពីបេសកកម្មជាមួយឥន្ទ្រីយ៍ក្រហម ១៨ គឺលោកវរសេនីយ៍ត្រី គង់ ឆាយហុង ខ្ញុំមើលពីលើឃើញមនុស្សកកស្រទាប់ នៅវាលចំណតយន្តហោះ ហាក់ដូចជាតេរង់ចាំចេញដំណើរទៅណា។ គ្រាប់ផ្លោងបាញ់ចូលវាលយន្តហោះស្ទើរតែគ្មានស្រាក។ មកដល់ទន្ទឹមនឹងវាលយន្តហោះ ឥន្ទ្រីយ៍ក្រហម១៨ត្រូវគ្រាប់យ៉ាងដំណំ ដែលធ្វើឱ្យយន្តហោះអស់សក្ដានុ-ពលទៅមុខលែងរួច ហើយបង្ខំឱ្យចុះចតនៅចន្លោះដីតូចមួយក្នុងតំបន់ផ្ទះមួយរយខ្នង។ យើងប្រញាប់ស្រែកឱ្យឥន្ទ្រីយ៍ក្រហមផ្សេងទៀតមកសង្គ្រោះ ដូចចិត្តឥន្ទ្រីយ៍ក្រហមដែលបើកបរដោយលោក គីរីរម្យ បានមកយកយើងហើយទម្លាក់យើងចុះនៅស្តាតអូឡាំពិក ជាទីដែលឧទ្ធម្ភាគចក្រជួបជុំគ្នា។ ខ្ញុំសម្រាកនៅស្តាតដោយពុំចេញទៅណាឡើយ។ ឯលោកគង់ ឆាយហុង បានចេញទៅក្រៅ បើតាមខ្ញុំដឹង គឺទៅជួបលោក អ៊ា ឆុង ហើយប្រហែលជាទទួលបញ្ជាថ្មីមួយទៀត ។

នៅម៉ោងប្រហែល១២អាធ្រាត្រ និងម៉ោង ១ទៀបភ្លឺ ខ្ញុំឃើញឧទ្ធម្ភាគចក្រមួយគ្រឿងដែលខ្ញុំដឹងថា បើកបរដោយ កែវ សាកាន - (8A) ហោះឡើងតែមួយសន្ទុះឃើញចុះមកវិញដោយមិនដឹងមូលហេតុអ្វី។ លុះព្រលឹមឡើងថ្ងៃទី ១៧ មេសា ១៩៧៥ ឧទ្ធម្ភាគចក្រទាំងអស់ត្រូវចាកចេញពីស្តាត ហើយចំណុចជួបគ្នាទៅសៀមរាប។ ខ្ញុំ និងលោក សរ ជិនសារេ (8A) ដែលមានផ្ទុកមនុស្ស១១នាក់ ហើយក្នុងនោះមានឥស្សរជនសំខាន់ម្នាក់ គឺលោកឡឹក សំអឿន។ យើងមកដល់សៀមរាបដោយសុវត្ថិភាព ប៉ុន្តែយើងក៏ដឹងដែរថា នេះជាដំណើរដ៏វែងឆ្ងាយ ហើយក៏មិនប្រាកដជាត្រឡប់មកវិញបានឬទេ ? ខ្ញុំមានគំនិតមួយថា ទេ អញត្រូវតែទៅយកគ្រួសារអញពីបាត់ដំបង ដើម្បីធ្វើដំណើរទៅជើងមេឃថ្មីនេះទាំងអស់គ្នា។ ភ្លាមនោះខ្ញុំបានរកគ្នា ដើម្បីមកបាត់ដំបង ប៉ុន្តែគ្មាននរណាម្នាក់ស្ម័គ្រស្មោះជាមួយនឹងខ្ញុំទេ។ ក៏ប៉ុន្តែមានទាហានម្នាក់ជាអ្នកបើកឡាន ដែលមិនដែលស្គាល់យ៉ាងម៉េចដែលហៅថាយន្តហោះ ស្រាប់តែស្រែកថា ខ្ញុំទៅជាមួយតេជគុណ



លោកអនុសេនីយ៍ទោ ឡៀម ជាន

តាមពិតខ្ញុំត្រូវការតែគ្នាទៅជាមួយតែប៉ុណ្ណោះ។ ភ្លាមនោះខ្ញុំរុញវាឡើងយន្តហោះ ហើយធ្វើដំណើរតម្រង់ទៅបាត់ដំបង។ ទៅដល់បាត់ដំបងខ្ញុំហោះក្រវែលមាត់ស្ទឹងក្បែរផ្ទះខ្ញុំ ហើយជាចៃដន្យដ៏អស្ចារ្យ ខ្ញុំឃើញប្រពន្ធខ្ញុំបណ្តើរកូនពីរនាក់ ម្នាក់អត់ខោ និងម្នាក់ទៀតអត់អាវ។ ខ្ញុំបង្ខំឱ្យឧទ្ធម្ភាគចក្រចុះនៅក្បែរមាត់ស្ទឹងហើយឱ្យតែកុងឡាននោះ ទៅហៅប្រពន្ធខ្ញុំនិងកូនមកជួបខ្ញុំ ហើយឱ្យទៅផ្ទះខ្ញុំប្រមូលបានខោអាវមួយកញ្ចប់ និងជីដូនម្នាក់ទៅជាមួយមកជាមួយផង។ មនុស្សម្នាចោមរោមយន្តហោះខ្ញុំជុំជិត តែគេពុំដឹងថា មានរឿងអ្វីកើតឡើងទេ។ ខ្ញុំប្រញាប់ហោះចេញពីទីនោះ ហើយបានត្រឡប់មកសៀមរាបវិញ ដោយសុវត្ថិភាព។ បេសកកម្មបានចប់ដោយជោគជ័យ។ មកដល់សៀមរាបគ្រួសារខ្ញុំសម្រាកបានបន្តិច ស្រាប់តែប្រហែលម៉ោង ៩ ទៅ ១០ យប់ ខ្ញុំចេញមកក្រៅស្រាប់តែបាត់មនុស្សអស់ពីកន្លែង ខ្ញុំស្ទើរតែអស់ព្រលឹងពីក្នុងខ្លួន ហើយព្រឺឆ្អឹងខ្នងខ្លាក ហើយគិតថា បើគេចេញទៅម្តេចក៏មិនប្រាប់ខ្ញុំផង។ ខ្ញុំឆ្លេឆ្លាទៅមុខអគារស្រាប់តែឃើញរថយន្តមួយដែលធ្លាប់ដឹក Pilot ចុះឡើងមកដល់ ហើយ Chauffeur បានប្រាប់ខ្ញុំថា អស់លោកគេចេញអស់ហើយ ហើយបើខ្ញុំចង់ចេញទៅវាល គេជូនទៅ។ ឥតប្រកែកមួយម៉ាត់ ខ្ញុំ និងគ្រួសារឡើងឡានទៅវាលយន្តហោះ ប្រហែលម៉ោង១០យប់ទៅហើយ។ នៅទីនោះមនុស្សមួយហ្វូងធំរង់ចាំនៅក្បែរឧទ្ធម្ភាគចក្រមួយ ហើយខ្ញុំឃើញ Gunner ម្នាក់ដែលខ្ញុំស្គាល់វា ហើយវាថាទាំងអស់គ្នាសុទ្ធតែគ្រួសារវា ហើយរាប់ទៅឃើញ ១៣ នាក់។ គ្មានពេលពិចារណាទេ ទាំងអស់គ្នានាំគ្នាឡើងណែនដូចកន្ត្រ ហើយហោះទាំងងងឹតឈឹង មកកាន់ឧត្តរមានជ័យ។ ដោយយន្តហោះធ្ងន់ពេក ហើយងងឹតទៀតផង យន្តហោះអុកដីខ្លាំង បណ្តាលឱ្យបាក់ជើងក្រោម ហើយបែកកញ្ចក់ខ្ទាយ ប៉ុន្តែជាកុសលគ្មាននរណាម្នាក់មានរបួសឡើយ ។ ទាំងអស់គ្នាលោតចុះពីយន្តហោះ ហើយគ្រាន់តែរលាស់អំបែងកញ្ចក់ចេញពីក្បាល និងខ្លួនតែប៉ុណ្ណោះ ហើយខ្ញុំរាប់ទៅឃើញ២៥នាក់ ៕